# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0041**

សម្ភាសន៍ជាមួយឈ្មោះ គិន ពៅ ភេទស្រី អាយុ៥៣ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម "នារីស្រែអំបិល"

មុខងារបច្ចុប្បន្ន "កសិករ"

ស្រុកកំណើតនៅភូមិព្រីង ឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ

រស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៥:៣៩

២៤ទំព័រ

វណ្ណៈ ខ្ញុំឈ្មោះសុខ វណ្ណៈមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ពៅៈ ចាស ។

វណ្ណៈ ខ្ញុំមកនេះគឺចង់ដឹងរឿងរ៉ាវនៅស្រុកម៉ាឡៃដើម្បីយកទៅសរសេរជាសៀវភៅមួយដែលទាក់ទងពីស្រុកម៉ាឡៃ ។

ពៅៈ ចាស ។

វណ្ណៈ ចឹងការសម្ភាសន៍របស់ខ្ញុំមីងអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរជាសៀវភៅបានទេ?

ពៅៈ មានអីបាន ។

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

ពៅៈ ខ្ញុំឈ្មោះគិន ពៅ ។

វណ្ណៈ ចឹងមីងអាយុប៉ុន្មានឆ្នាំហើយ?

ពៅៈ ខ្ញុំអាយុ៤៩ឆ្នាំ ។

វណ្ណៈ គ្រួសារមីងឈ្មោះអីដែរ?

ពៅៈ គ្រួសារមីងឈ្មោះរស់ ប៉េង ។

វណ្ណៈ ហើយមានកូនប៉ុន្មាននាក់?

ពៅៈ មានកូន៤នាក់ ។

វណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ពៅៈ ប្រុសបីស្រីមួយ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

វណ្ណៈ សព្វថ្ងៃមីងប្រកបមុខរបរអ្វីដែរ?

ពៅៈ សព្វថ្ងៃធ្វើចំការបន្តិចបន្តួចហ្នឹង ។

វណ្ណៈ ឪពុកមីងឈ្មោះអី?

ពៅៈ ឪពុកឈ្មោះគិន មិន ។

វណ្ណៈ ម្តាយ?

ពៅៈ ម្តាយឈ្មោះ ណាង មិនស្គាល់កុងមិនដឹងជាឈ្មោះអី ។

វណ្ណៈ ចឹងគាត់សព្វថ្ងៃស្លាប់ឬរស់?

ពៅៈ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ចឹងមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

ពៅៈ បងប្អូនបង្កើតមាន៧នាក់ ។

វណ្ណៈ ចឹងនៅរស់ទាំងអស់?

ពៅៈ អត់ទេ គឺស្លាប់ជំនាន់ប៉ុល ពតនោះអស់៤នាក់ ក្រោយមកគាត់ចាស់ៗស្លាប់អស់ទៀតទៅសព្វថ្ងៃនៅសល់តែពីរនាក់ទេ ។

វណ្ណៈ ចឹងស្លាប់សម័យខ្មែរក្រហមបួននាក់?

ពៅៈ ចាស ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យមីងរៀបរាប់ថាបងប្អូនស្លាប់ដោយសារមូលហេតុអីនិងមីងធ្លាប់ជួបហេតុការណ៍អីខ្លះ សូមមីងជួយរៀបរាប់ផង?

ពៅៈ ចាស ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងពីស្រុកកំណើតសិន មីងមានស្រុកកំណើតនៅណា?

ពៅៈ ស្រុកកំណើតខ្ញុំនៅខេត្តតាកែវ ស្រុកព្រៃកប្បាស ឃុំអង្គាញ់ ភូមិព្រីង ។

វណ្ណៈ ឥឡូវនេះមីងរស់នៅភូមិអី?

ពៅៈ សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យមីងរៀបរាប់រឿងរ៉ាវរបស់មីងថា ពីតូចរៀននៅសាលាណា? ហើយជីវិតមីងជួបបញ្ហាអ្វីខ្លះ? បានរហូតមកដល់ព្រំដែននេះ មីងជួបហេតុការអីខ្លះរហូតមកដល់បច្ចុប្បន្ននេះ?

ពៅៈ តាំងពីតូចមកខ្ញុំនៅរួមរស់ជាមួយឪពុកម្តាយបងប្អូនក្រុមគ្រួសារខ្ញុំហ្នឹង បានអាយុ១៨ឆ្នាំ កាលខ្ញុំមានអាយុ៧ឆ្នាំខ្ញុំបានរៀននៅសាលាវត្តអង្គាញ់ហ្នឹងតែម្តង ។

វណ្ណៈ ចឹងកាលហ្នឹងរៀនបានថ្នាក់ទីប៉ុន្មាន?

ពៅៈ កាលហ្នឹងខ្ញុំរៀនបានត្រឹមថ្នាក់ទី១១ "ចាស់" កើតរដ្ឋប្រហារឆ្នាំ៧០ ។

វណ្ណៈ ចឹងឈប់រៀនដោយសាកើតរដ្ឋប្រហា?

ពៅៈ ចាស!រដ្ឋប្រហាឆ្នាំ៧០ហ្នឹងគ្រូរត់មកភ្នំពេញអស់ទៅខ្ញុំក៏គ្មានបានរៀនតទៅទៀតណាអត់ ដល់កើតសម័យបដិវត្តនិងទៅខ្ញុំរៀនបានខ្លះទៀតតាមភូមិ ។

វណ្ណៈ រៀនសម័យបដិវត្តហ្នឹងនៅឆ្នាំ១៩៧៥?

ពៅៈ អត់ទេ កាលឆ្នាំ៧៣-៧៤ហ្នឹងដល់៧៥ខ្ញុំមិនបានរៀនទេ ។

វណ្ណៈ ចឹងឆ្នាំ៧៣មីងនៅណា?

ពៅៈ ខ្ញុំនៅភូមិជាមួយឪពុកម្តាយនៅឡើយ ដល់ឆ្នាំ៧៤ខែ៧គេឲ្យចេញមកនៅតាមឃុំ ។

វណ្ណៈ មកនៅហ្នឹងធ្វើអី?

ពៅៈ ហ្នឹងមកនៅកងចល័តហើយ នៅតាមឃុំដូចជាដើរលើកទំនប់ខាងឃុំចឹងទៅ ដល់រំដោះឆ្នាំ៧៥បានចេញមកនៅស្រុក ។

វណ្ណៈ កាលហ្នឹងធ្វើកងចល័តឃុំ?

ពៅៈ ចាស ។

វណ្ណៈ ចឹងឆ្នាំ៧៥?

ពៅៈ ឆ្នាំ៧៥អង្គការរើសមកនៅតាមភូមិភាគតែម្តង កាលនោះនៅស្រុកបាន៧ខែបានមកនៅភូមិភាគតែម្តង ។

វណ្ណៈ នៅភូមិភាគអី?

ពៅៈ នៅភូមិភាគនិរតីហ្នឹងតែម្តង ទៅលើកទំនប់នៅអង្គរបុរី ។

វណ្ណៈ ចឹងមកនៅភូមិភាគនិរតីលើកទំនប់?

ពៅៈ ចាស!នៅហ្នឹងបានមួយឆ្នាំបានអង្គការបញ្ជូនខ្ញុំទៅស្រែអំបិល ។

វណ្ណៈ ចឹងនៅឆ្នាំ៧៦?

ពៅៈ ខ្ញុំនៅឆ្នាំ៧៦នៅធ្វើស្រែអំបិលបានមួយឆ្នាំបានទៅកំពង់សោមទៀត ដើរជុំវិញប្រទេស ។

វណ្ណៈ ចឹងកាលទៅកំពង់សោមគេឲ្យធ្វើអី?

ពៅៈ ទៅកំពង់សោមគេឲ្យធ្វើចំការកៅស៊ូហ្នឹង ។

វណ្ណៈ ចឹងទៅធ្វើចំការកៅស៊ូរហូតឬមួយយ៉ាងម៉េច?

ពៅៈ អត់ទេ នៅចំការកៅស៊ូខែ១២ឆ្នាំ៧៧ គេបញ្ជូនខ្ញុំមកនៅភ្នំពេញវិញ ។

វណ្ណៈ ចឹងពេលមកដល់ភ្នំពេញធ្វើខាងអី?

ពៅៈ នៅភ្នំពេញខ្ញុំធ្វើជាកម្មកររោងចក្រខាងកាត់ដេរ ។

វណ្ណៈ រួចយ៉ាងម៉េចទៀត?

ពៅៈ ខ្ញុំនៅរោងចក្រកាត់ដេរហ្នឹងរហូតដល់ឆ្នាំ៧៩ នៅពេលវៀតណាមចូលមកបានគេជម្លៀសចេញពីភ្នំពេញមក ។

វណ្ណៈ កាលហ្នឹងយួនចូលមកយើងរត់ដោយខ្លួនឯង?

ពៅៈ អត់ទេ កាលហ្នឹងគេគៀមក គេថាឲ្យមកលិចៗ ចេះតែដើរមកអត់បាយទឹកទាំងអស់គ្នា ។

វណ្ណៈ ចឹងចេញមកមុខយួនចូលមក?

ពៅៈ អត់ទេ ខ្ញុំចេញថ្ងៃទី៧មករាបណ្ដោយ នៅម៉ោង៧ព្រឹកខ្ញុំចេញមក កាលហ្នឹងគេបិុសរត់ចោល ហើយគេទៅដាស់ខ្ញុំក្រោយគេ កាលហ្នឹងអាយុ១៧ឆ្នាំកំពង់ពេញដេក គេថាយួនអាករង់ចាប់ឥឡូវ ហើយនៅដេកធ្វើអី ដល់ហើយងើបក្រោយគេអត់មានបានខោអាវរលីងខ្ញុំ កាលហ្នឹងដើរតាមភូមិភាគបស្ចិមហ្នឹងមកអត់បាយអត់ទឹក ។

វណ្ណៈ កាលរត់មកមានគ្នាច្រើនទេ?

ពៅៈ គ្នាច្រើនណាស់ មានមនុស្សរាប់ម៉ឺនរាប់ពាន់នាក់ ខ្ញុំដើររហូតអត់មានឡានជិះទេ ដើរតាំងពីភ្នំពេញរហូតបានមកដល់ហ្នឹងឯង ។

វណ្ណៈ ចឹងដើររយៈពេលប៉ុន្មានខែបានមកនៅទីនេះ?

ពៅៈ យូរដែលគិតទៅខ្ញុំមកដល់ម៉ាឡៃហ្នឹងនៅខែ១២ឆ្នាំ១៩៧៩ ចឹងយើងរត់ចេញតាំងពីខែ១ដល់ខែ១២ខ្ញុំបានឈរនៅម៉ាឡៃហ្នឹង ខ្ញុំតាំងពីហ្នឹងទៅដល់គ្រាងអូរអន្ទក់ណានោះ ។

វណ្ណៈ ចឹងមីងរៀបរាប់មើលថា ហេតុអីខ្លះនៅតាមផ្លូវមកហ្នឹង?

ពៅៈ តាមផ្លូវមកស្លាក់នៅចឹងទៅ គេរើគ្នាក៏រត់មកទៀតទៅណាស់ សំខាន់មកដល់បរវេលនេះគេដេញបាញ់តែម្ដងខ្ញុំរត់កាត់គ្រាប់តែម្ដង រត់ឆ្លងទឹកមកនៅបរវេលហ្នឹងបានប្រហែលជាកន្លះខែ ដល់ក្រោយមកបានមកនៅបឹងបេង ដល់នៅបឹងបេងទៅអត់អីហូបនាំគ្នាហូបតែស្លឹកឈើលាយបបរទៅអង្ករមួយកំប៉ុងគ្នា១០នាក់ គាស់មើមទាល់អីបបរដល់ហូបមិនឆ្អែតបានគេឲ្យទៅនៅគ្រាងដល់ទៅនៅគ្រាងហ្នឹងបានប៉ុន្មានបានមួយខែទៀត អត់មានអីហូប ហូបគល់ចេកលាយជាមួយដំឡូវបន្ទាខ្ញុំហើយអ្នកទៅជីកអត់មានចបជីកទៀត ជីកនិងឈើគ្គឹះបានទៅខ្ញុំគេឲ្យធ្វើចុងភៅខ្ញុំគេគ្រប់គ្រងកុមារ១២នាក់ ។

វណ្ណៈ ចឹងមានកុមាររត់មកជាមួយ?

ពៅៈ ចាស!មានកុមារកំព្រាអត់មានម៉ែឪដូចថាគេយកមកដាក់ក្នុងមន្ទីរនោះ ដល់ពេលរត់ម៉ែឪបងប្អូនទៅខ្ញុំហ្នឹងគេឲ្យមើលកុមារមួយក្រុម ។

វណ្ណៈ ចឹងនៅតាមផ្លូវហ្នឹង?

ពៅៈ ចាស!តាមផ្លូវ៧៩មកហ្នឹង ចេះនាំក្មេងៗហ្នឹងបេះស្លឹកឈើហូបទៅ ។

វណ្ណៈ ចឹងកុមារដែលមកជាមួយហ្នឹងបានមកដល់ព្រំដែនទាំងអស់គ្នាឬមួយមានស្លាប់តាមផ្លូវ?

ពៅៈ មានស្លាប់ដូចថាក្រោយមកពិបាកពេក អត់មានអីហូបពេកទៅ មានបងប្អូនក្នុងភូមិគេសុំយកទៅនៅជាមួយទៅ ខ្លះមាននៅរស់នៅចំការស្រូវចក្រីនោះមានប្ដីមានប្រពន្ធអស់ហើយ ។

វណ្ណៈ បាទ ។

ពៅៈ ហើយខ្ញុំពិបាកពេកខ្ញុំរត់ចេញពីពួកហ្នឹងទៀត ស្គាល់គ្នាពីរនាក់បងស្រៀងមួយឥឡូវនៅស្វាយ ។

វណ្ណៈ ចឹងក្រោយមករត់ចេញពីកុមារទៀត?

ពៅៈ ចាស! ពីរនាក់ហ្នឹងអត់បាយពេកអត់មានអីហូបនោះ បងស្រៀងបបួលខ្ញុំរត់ រត់យប់ទៀតរត់កាត់ព្រៃបើគេដឹងគេយកយើងទៅកន្លែងអប់រំទៀត ។

វណ្ណៈ បាទ ។

ពៅៈ ចឹងខ្ញុំរត់ចេញទាំងយប់ រត់ចេញមកនៅអង្គភាពចាស់ ដូចថានៅរោងចក្រធ្លាប់ស្គាល់គ្នានោះ តែខ្ញុំរត់មកនៅជាមួយបងហ្នឹងសព្វថ្ងៃគាត់នៅខ្លាងរាប់នោះ ។

វណ្ណៈ ចឹងខ្ញុំចង់សួរមីងថាកុមារដែលបានរត់តាមមកជាមួយមីង ឥឡូវមីងមានដឹងថានៅរស់ប៉ុន្មាននាក់ ?

ពៅៈ នៅសល់តែពីរនាក់ទេ ពីរនាក់ទៀតស្លាប់បាត់ហើយដូចថាបងគាត់គេចោទថាក្បត់គេចាប់យកទៅសម្លាប់ទៅ ។

វណ្ណៈ ចឹងពីរនាក់ហ្នឹងឈ្មោះអី?

ពៅៈ នៅសព្វថ្ងៃហ្នឹងមានឈ្មោះ ខុមមួយនិងឈ្មោះរិទ្ធមួយ ។

វណ្ណៈ ឈ្មោះនៅណា?

ពៅៈ នៅចក្រី ។

វណ្ណៈ ចក្រីនៅណាវិញទៅ?

ពៅៈ ចក្រីនៅខាងសំពៅលូននោះ គេមានប្ដីប្រពន្ធអស់ហើយខ្ញុំមិនសូវដែលជួបដែរ ។

វណ្ណៈ ចឹងឈ្មោះរិទ្ធ?

ពៅៈ រិទ្ធហ្នឹងនៅខាងសំពៅលូនហ្នឹងដែរ ។

វណ្ណៈ ហើយប៉ុន្មាននាក់រត់បែកគ្នានិងស្លាប់តាមផ្លូវ?

ពៅៈ ចាស ។

វណ្ណៈ ហើយយ៉ាងម៉េចទៀត?

ពៅៈ ក្រោយមកខ្ញុំរត់ទៅនៅជាមួយបងដែលធ្លាប់នៅជាមួយគ្នានៅភ្នំពេញនោះ ដល់នៅជាមួយគាត់ទៅបានគេជម្លៀសខ្ញុំឲ្យមកនៅម៉ាឡៃហ្នឹង ចេញពីត្រាងមក ។

វណ្ណៈ  គ្រាងហ្នឹងនៅខាងណាវិញ?

ពោះ  គ្រាងហ្នឹងនៅខាងស្រុកកំរៀង ។

វណ្ណៈ  ចឹងមកដល់ម៉ាឡៃនៅខែ១២ឆ្នាំ១៩៧៩?

ពោះ  ចាស ។

វណ្ណៈ  ចឹងកាលមកដល់ម៉ាឡៃហ្នឹងជួបហេតុអីខ្លះទៅ  ហើយមីងស្រីចឹងមានទៅសមរភូមិមុខវៃជាមួយយួនទេ?

ពោះ  ខ្ញុំកាលហ្នឹងគ្រាន់តែគេឲ្យជួយដឹកជញ្ជូនអង្ករ  ខាងហ្នឹងមានខាងរដ្ឋគេដោះស្រាយសេដ្ឋកិច្ចចេញចូលពីថៃនោះណាស់ ។

វណ្ណៈ  បាទ ។

ពោះ  ជួយដូនជញ្ជូនអង្ករមកពីខាងដីថៃ មកដាក់ដីខ្មែរចែកឲ្យប្រជាជនហូប ។

វណ្ណៈ  កាលហ្នឹងអង្ករខាងកាកបាទឬមួយយ៉ាងម៉េច?

ពោះ  កាកក្របាទចូល  ពួកជំនួយខាងជំនួយ ។

វណ្ណៈ  ចឹងកាលមីងមកដល់ទឹកដីម៉ាឡៃនេះដំបូងឃើញមានព្រៃ?

ពោះ  ព្រៃសុទ្ធ  សុទ្ធតែព្រៃតែម្តង  ព្រៃអត់មានផ្ទះអីទេ  មានតែផ្ទះខ្ទមតូចៗ  កាលហ្នឹងពួកខ្ញុំធ្វើខ្ទមស្រីៗកាប់ឫស្សីខ្លួនឯងធ្វើខ្ទមទៅ  ម៉ាក្រុមៗនៅទៅគ្មានម៉ែឪទេម្នាក់ៗ ។

វណ្ណៈ  កាលហ្នឹងនៅទីនេះមានសត្វព្រៃទេ?

ពោះ  មានស្វាមានទោចមានខ្លា ។

វណ្ណៈ  ដំរីមានទេ?

ពោះ  ដំរីមាន  មកដំបូងសុទ្ធតែដំរី  ជ្រូកព្រៃ  សម្បុរដំរី  ខ្លាមិនសូវឃើញទេ  ច្រើនពួៗគេឃើញគេទៅមុខ  បើដំរីឃើញហ្នឹងភ្អែកតែម្តង ។

វណ្ណៈ  បាទ ។

ពោះ  ស្វាអីហ្នឹង ។

វណ្ណៈ  ចឹងមីងជាស្រីចឹងគេមានបំពាក់អាវុធឲ្យវៃជាមួយខាងនោះវិញទេ?

ពោះ  ស្រីៗអត់ទេ  ស្រីៗមាននៅយាមតាមកន្លែងនៅចឹងទៅណា ។

វណ្ណៈ  ចឹងនៅខាងនោះមានវៃលុកមកទេ  ខាងរដ្ឋាភិបាលខាងក្នុងនោះ?

ពោះ  ខាងនោះវៃ ។

វណ្ណៈ  វៃមកដល់ហ្នឹងដែរ?

ពោះ: ចាស!វ៉ៃគ្នានៅដូវបំបែកនេះរត់ ខ្ញុំរត់មកយកអង្គរនេះមានតែគ្នាពីរនាក់ទេ កាលគេបាញ់គ្នាដូវបំបែកនេះនោះ កាលហ្នឹងស្ងាត់ឈឹងគេចូលដីថៃអស់រលីងនៅពីរនាក់មីណោម ភ័យចង់ងាប់ ហើយភ័យបន់ដូនតាសព្វគ្រប់អស់ហើយខ្ញុំនោះ ។

វណ្ណៈ: ចឹងនៅពេលកងកំលាំងខ្មែរក្រហមវ៉ៃចាញ់រត់ចូលដីថៃ ថៃអត់មានថាអីទេ?

ពោះ: អត់អីទេ ។

វណ្ណៈ: ចឹងមានតែជួយ?

ពោះ: ចាស ។

វណ្ណៈ: ចឹងហេតុអីបានជាថៃចេះតែជួយយើងកាលជំនាន់ហ្នឹង?

ពោះ: ខ្ញុំមិនដឹងជាមានការទំនាក់ទំនង ។

វណ្ណៈ: ចឹងក្រែងលោថៃមានផលប្រយោជន៍ពីខ្មែរក្រហមទេ បានជាចេះតែជួយប្តូរយ៉ាងម៉េច?

ពោះ: ខ្ញុំមិនបានដឹងដែររឿងហ្នឹង ។

វណ្ណៈ: កាកបាទ គេមកតាមអង្គការសហប្រជាជាតិ?

ពោះ: ចាស ។

វណ្ណៈ: ចឹងថៃមានសារៈប្រយោជន៍ពីអង្គការសហប្រជាជាតិយើងមិនដឹងដែរ?

ពោះ: ចាស!ដូចថាអ្នកធំៗខាងលើគេទំនាក់ទំនងគ្នាទៅ ។

វណ្ណៈ: បាទ ។

ពោះ: ទំនាក់ទំនងតាមរដ្ឋាភិបាលថៃអីទៅណាស់ ។

វណ្ណៈ: បាទ ។

ពោះ: កាលហ្នឹងខ្ញុំដឹងច្បាស់ថាលោកប្រេមអីគាត់មានទំនាក់ទំនងជាមួយខ្មែរយើងណាស់ ។

វណ្ណៈ: លោកប្រេមហ្នឹងជនជាតិ?

ពោះ: លោកប្រេមហ្នឹងថៃតែម្តង ទាហានថៃធំរងពីស្តេចថៃហ្នឹងហើយ ។

វណ្ណៈ: បាទ ។

ពោះ: លោកប្រេមនៅតែរាល់ថ្ងៃហ្នឹង គាត់ចាស់ហើយ កាលហ្នឹងគាត់មេធំ កាលហ្នឹងច្បាស់ជាងគេគឺលោកប្រេមតែម្តង កាលហ្នឹងពុកវាំនៅជាមួយភ្ញៀវថៃដែលនោះ ។

វណ្ណៈ: ចឹងគាត់ចូលមកដែរ?

ពោះ: ចាស!គាត់ខស្សាហ៍ចេញចូល ចូលមកមើលបងប្អូនខ្មែរយើងនៅនេះយ៉ាងម៉េចៗហ្នឹងណាស់ ។

វណ្ណៈ: បាទ ។

ពោះ: គាត់ជាមេទាហានថៃ ។

វណ្ណៈ ចឹងនៅហ្នឹងកងកំលាំងយើងវៃជាមួយយួនជាខាងរដ្ឋាភិបាលខាងក្នុងអីមានរបួសមានស្លាប់អីទេ?

ពៅៈ មានដូចគ្នា ។

វណ្ណៈ ចឹងមានដូចគ្នា?

ពៅៈ ចាស!ស្លាប់ដូចតែគ្នាហ្នឹង ប៉ះថ្ងៃណាបីបួននាក់មេក្រូទ្រហឹងចឹងទៅ ។

វណ្ណៈ ចឹងមានគ្រុនចាញ់ស្លាប់ទេខាងខ្មែរក្រហមអី?

ពៅៈ មានគ្រុនចាញ់ស្លាប់ច្រើនណាស់ កាលរត់មកដល់ដំបូង ខ្ញុំអីសុទ្ធស្លាប់ម្ដងហើយហ្នឹងឈឺភ្ញាក់ដឹងខ្លួនឡើងឃើញគេយំទ្រហឹង អត់មានដឹងខ្លួនទេ សួរគេថាយំអី គេយំអីទៀតវាសន្លប់មិនដឹងខ្លួនផង ។

វណ្ណៈ ចឹងកាលហ្នឹងមានថ្នាំសង្កូវអីទៅជាវិញទៅ?

ពៅៈ ចាស!កាលហ្នឹងដូចថាមានថ្នាំមានអីពេទ្យ ដូចថាយើងខានប្រើថ្នាំយូរណា ។

វណ្ណៈ បាទ ។

ពៅៈ ដល់ចឹងគេមានថ្នាំតែមួយម្ហូលពីរម្ហូលចាក់ឲ្យយើងក៏ជាដែរ ។

វណ្ណៈ បាទ ។

ពៅៈ ចាក់ទៅដឹងខ្លួនវិញទៅ ខ្ញុំងើបឡើងឃើញគេយំទ្រហឹងរស់វិញទៅ ។

វណ្ណៈ ចឹងមឹងមានគិតស្ដាយថា នៅពេលយួនចូលមកចឹងគួរតែរត់ទៅផ្ទះមិនគួររត់មកចេះវាវេទនាចឹង?

ពៅៈ កាលហ្នឹងស្ដាយណាស់ខ្ញុំ ខ្ញុំចេញផុតពីភ្នំពេញហួសពោធិចិនតុងមក មកដល់កន្លែងវៃថ្មត្រពាំងក្រឡឹងហ្នឹង គេបបួលខ្ញុំទៅផ្ទះវិញដែលគេអ្នកនៅភូមិជាមួយខ្ញុំពីរនាក់ តែខ្ញុំមិនហ៊ានទៅព្រោះខ្ញុំចេញមកហ្នឹងរថក្រោះគេដេញបាញ់ហើយហ្នឹង ។

វណ្ណៈ បាទ ។

ពៅៈ រថក្រោះបាញ់គ្នាមកហួសពោធិចិនតុងហើយហ្នឹង ដល់ចឹងខ្ញុំមិនហ៊ានត្រឡប់ក្រោយទៅវិញម្យ៉ាងនឹកឃើញថាទៅដល់ផ្ទះ ខ្លាចគេគៀឪពុកម្ដាយចេញពីភូមិអស់មិនដឹងជាទៅណា ។

វណ្ណៈ បាទ ។

ពៅៈ ហើយម្យ៉ាងទៀតខ្លាចគេចាប់តាមផ្លូវ ម្យ៉ាងខ្លួនឯងស្រីផងមិនហ៊ានទៅ នឹកឃើញថាគេទៅណាច្រើនទៅហ្នឹងគេទៅចឹងចេះតែមកតាមគេទៅ គ្នាច្រើននោះយើងមិនហ៊ានត្រឡប់ទៅក្រោយវិញទេ ខ្ញុំមកដល់គ្រាងហើយគេបបួលទៅវិញទៀតតែខ្ញុំមិនហ៊ានទៅខ្ញុំខ្លាចគេបាញ់គ្នាតាមផ្លូវ ។

វណ្ណៈ ចឹងមាននឹកស្រុកនឹកឪពុកម្ដាយទេ?

ពៅៈ នឹកនោះវាមហានឹកហើយនឹកសែននឹក ថ្ងៃណាក៏ដេកយំចឹងទៅនឹកពេកនោះ ។

វណ្ណៈ ចឹងដល់ហើយមីងរៀបការនៅឆ្នាំណាដែរ?

ពោះ ខ្ញុំការឆ្នាំ៨៥ខែ១ ។

វណ្ណៈ ការឆ្នាំ៨៥ខែ១ចាំច្បាស់ទៀត?

ពោះ ចាស!ចាំ ។

វណ្ណៈ ចឹងកាលដែលការហ្នឹងមានប្រពៃណីមានលោកសង្ឃធម្មតាហើយ?

ពោះ ខ្ញុំមានចាស់ទុំមិនមានលោកទេ កាលហ្នឹងគេកំពង់តែវៃគ្នា ពីនេះទៅវត់ទៅព្រំដែនរត់ទៅដីថៃនោះ ចឹងវាច្របូកច្របល់ច្រើនពេកទៅថៃនោះ ។

វណ្ណៈ បាទ ។

ពោះ ចឹងមួយរត់ទៅថៃទៅជំរំ គេមានជំរំខ្មែរភាសខ្លួនកាកបាទក្រហមចឹងញ៉ឹមទៅណាស់ទៅមួយផ្នែក មួយផ្នែកទៀតជំរំខ្មែរក្រហមកាន់កាប់មួយផ្នែក ។

វណ្ណៈ បាទ ។

ពោះ ដល់ចឹងទៅខ្ញុំមានគូរដណ្ដឹងដូចពុកវាហ្នឹងគាត់សួរខ្ញុំទុក៥ឆ្នាំហើយ ចឹងចាស់ទុំបងប្អូនរាប់អានថា ម៉េចមិនព្រមការឥឡូវត្រូវបែកគ្នា ។

វណ្ណៈ បាទ ។

ពោះ ឯងត្រូវគេអូសទៅជំរំចឹង គាត់គេត្រូវឲ្យគាត់នៅធ្វើសង្គ្រាមនៅនេះ ។

វណ្ណៈ បាទ ។

ពោះ ចឹងទៅបងប្អូនគេនាំគ្នាទិញមាន់ ទិញចេកមកគេចាប់ខ្ញុំផ្សំផ្គុំទៅមួយថ្ងៃហ្នឹងប្អូនដប់ម្ភៃគូរ ។

វណ្ណៈ ការច្រើនយ៉ាងនេះ ការដូចជាជំនាន់ខ្មែរក្រហមចឹង?

ពោះ ចាស!ជំនាន់ហ្នឹងនៅក្នុងខ្មែរក្រហមគ្រប់គ្រងដដែល ។

វណ្ណៈ តែយើងរំដោះមកហើយវា៧៩-៨០-៨១ហើយចឹងគេការនៅតែរបៀបហ្នឹងដែរ?

ពោះ ចាស!ដូចគ្នាហ្នឹង ។

វណ្ណៈ ចឹងមិនមានភ្លេងប្រពៃណីដែរ?

ពោះ អត់មានទេ ។

វណ្ណៈ ក្រែងមានសិល្បៈអីដែរ មានប្រពៃណីដែរ?

ពោះ អត់ទេ អត់ទាន់មានទេ ។

វណ្ណៈ ចឹងចាប់ការបានកូនប្អូនដែរ?

ពោះ ចាស!មាន ការខ្ញុំនៅមានរូបថតតើ ការខ្ញុំបានចាស់ៗប្អូនដប់នាក់ហើយបានគេចាក់ភ្លេងការម៉ាញ៉ៅហ្នឹងឯង ។

វណ្ណៈ ចឹងកាលឆ្នាំ៨៥ហ្នឹងរៀបការ២០គូរដែរ?

ពៅៈ ចាស!២០គូរ ។

វណ្ណៈ ចឹងពីណាជាគណៈអធិបតីចូលរួម?

ពៅៈ អត់ទេ មានតាអាចារ្យគាត់ធ្វើឲ្យ តែឥឡូវគាត់ខូចអស់ច្រើន មានអ៊ីខែម មានអ៊ី ម៉ អ៊ី ឌឿន ខ្មោចបង រីម ប្រធានមានបងឡេងមួយ កាលហ្នឹងគេការច្រើនគូរ តែថាមួយគូរការផ្សេងតែជិតៗគ្នាចឹងទៅណាស់ ។

វណ្ណៈ ចឹងកាលឆ្នាំ៨០-៨១-៨២អីហ្នឹងមីងអត់មានទៅជញ្ជូនគ្រាប់អីទេ?

ពៅៈ ខ្ញុំ៨១-៨២នៅជានារីដឹកជញ្ជូននៅឡើយហ្នឹង ។

វណ្ណៈ ចឹងមានដឹកជញ្ជូនគ្រាប់អីទេ?

ពៅៈ មានដឹកជញ្ជូនគ្រាប់ ។

វណ្ណៈ ចឹងអត់មានកាន់កាំភ្លើងឡើងវ៉ៃទេ?

ពៅៈ អត់ទេ ។

វណ្ណៈ ចឹងគ្រាប់មីនដែលមានច្រើនហ្នឹងខាងណាដាក់ខ្លះ?

ពៅៈ មីនមានច្រើនហ្នឹងដាក់ទាំងសងខាង ។

វណ្ណៈ ចឹងដាក់ទាំងអស់គ្នា?

ពៅៈ ខាងនេះចេញទៅខាងនោះមកខាងនោះដាក់មួយសារទៅ ដាក់ម្តងម្នាក់ ។

វណ្ណៈ ចឹងមីងនៅខាងដឹកសម្ភារហ្នឹងមីងមានដឹងថាសម្ភារហ្នឹងមកពីខាងណាទេ?

ពៅៈ សម្ភារហ្នឹងសុទ្ធតែពីខាងចិន របស់ចិនតែម្តងមីនអីគ្រាប់កាំភ្លើងចិន ។

វណ្ណៈ ចឹងមីងកាលហ្នឹងមានស្គាល់មេបញ្ជាការអីទេ កាលហ្នឹង?

ពៅៈ ខ្ញុំស្គាល់ច្រើនដែលតែខ្លះគាត់ស្លាប់អស់ហើយ គាត់នៅគ្នាតិចណាស់ឥឡូវ ។

វណ្ណៈ មានឈ្មោះអីខ្លះមីង?

ពៅៈ ខ្ញុំស្គាល់មេធំៗសព្វថ្ងៃមានបងសុខ ភាព ។

វណ្ណៈ ចឹងតា សុខ ភាពគាត់កាន់ក្រោយគេតាមពិត?

ពៅៈ ពីមុនមកបងដុនអីជាមួយតា សុខ ភាពហ្នឹងតែគាត់ស្លាប់ ។

វណ្ណៈ ចឹងតា ដុនហ្នឹងស្លាប់ហើយ?

ពៅៈ ស្លាប់ហើយនៅមេៗក្រោយៗពួកបងជាតអីនៅ ។

វណ្ណៈ ចឹងបងជាតហ្នឹងគាត់ជាបញ្ជាការដែរ?

ពៅៈ ចាស!គាត់ជាបញ្ជាការ ។

វណ្ណៈ ចុះតា ហុង?

ពោះ តា ហុងគាត់មិនសូវនៅប្រេកនេះផង តា ហុង ស្គាល់ដែលតែគាត់មិនសូវនៅនេះគាត់ច្រើនតែនៅប្រេកភ្នំឆត្រ ។

វណ្ណៈ បាទ ។

ពោះ គ្រាន់តែធ្លាប់ស្គាល់គាត់ ។

វណ្ណៈ ចឹងមានពីណាទៀត?

ពោះ មាន តា អៀង សារី ។

វណ្ណៈ តា អៀង សារីគាត់ជាបញ្ញការធំ?

ពោះ តា អៀង សារីគាត់គ្រប់គ្រងផ្នែកក្រសួងការបរទេស ។

វណ្ណៈ បាទ ។

ពោះ ទំនាក់ទំនងក្រសួងការបរទេស តែគាត់មិនសូវនៅនេះទេគាត់ចេញចូលៗ ។

វណ្ណៈ ចឹងតា កែវ ពក តា សុន សេនហ្នឹងគាត់មានមកនៅតំបន់នេះទេ?

ពោះ គាត់អត់មាននៅនេះទេ ។

វណ្ណៈ ចឹងមានពីណាខ្លះនៅតំបន់នេះមេធំៗ ?

ពោះ នៅតំបន់នេះមានតែ តា អៀង សារីហ្នឹងឯងគាត់គ្រប់គ្រងក្រសួងការបរទេស ។

វណ្ណៈ បាទ ។

ពោះ ចឹងប្រេកម៉ាឡៃហ្នឹងខ្ញុំដឹងថាជំនាន់សង្គ្រាម ប្រេកម៉ាឡៃនេះជាប្រេកធំមួយសម្រាប់សេដ្ឋកិច្ចចេញចូលតំបន់ខ្មែរក្រហមដូចថាម៉ាជីនារជាយដែន ។

វណ្ណៈ បាទ ។

ពោះ មានប្រេកម៉ាឡៃហ្នឹងឯងធំជាងគេនោះ មានខាងអន្តរជាតិមានប្រទេសជប៉ុន មានកូរេ មានចិន មានឥណ្ឌា មានសេរីឡាំងកាគេមកប្រេកនេះឯង ។

វណ្ណៈ ចឹងមានជនបរទេសចូលមកដល់ស្រុកម៉ាឡៃហ្នឹងដែរ?

ពោះ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងរបហែលជាឆ្នាំណា?

ពោះ កាលហ្នឹងដឹងជាឆ្នាំណាប្រហែលជាឆ្នាំ៨៣អីហ្នឹង ៨៣និង៨៤ហ្នឹងចូលពេញទំហឹងហើយពួកកូរេមកលេងសិល្បៈកាលហ្នឹងនោះ នេះអ្នកខាងបំរើភ្ញៀវដែរ ។

វណ្ណៈ មួយណាខាងបំរើភ្ញៀវ?

ពោះ នេះអ្នកបំរើភ្ញៀវដែលតើ ។

វណ្ណៈ ចឹង៨៣-៨៤មានភ្លៀវមានផ្ទះអីទេ?

ពៅៈ កាលហ្នឹងមានហើយ មានផ្ទះធំៗខ្លះហើយ មានផ្ទះ៥ម៉ែត្រ ៦ម៉ែត្រអីមាន អ្នកមានប្តីមានប្រពន្ធមានតែយើងនៅជានារីដឹកជញ្ជូនមិនទាន់មានទេ ។

វណ្ណៈ បាទ ។

ពៅៈ នារីដឹកជញ្ជូនមានផ្ទះឈើវែងប្រក់ស្បៅទៅរនាបឬស្សីហ្នឹងចឹងទៅ ។

វណ្ណៈ ចឹងកាលសម្តេចចុះមកសារតាំងហ្នឹងនៅឆ្នាំណា?

ពៅៈ ចឹងសម្តេចមកសារតាំងនៅឆ្នាំ៨៤(អ្នកនៅជិតនិយាយថា សម្តេចមកសារតាំង តាំងពីឆ្នាំ៨២) មីងពៅនិយាយវិញថា សម្តេចមកបានពីសារទេ បានបីសារហ្នឹងខាងក្នុងវៃមកហ្នឹង សម្តេចចេញមកបានប៉ុន្មានថ្ងៃ ចេញបានតែបីថ្ងៃទេគេវៃនោះ ។

វណ្ណៈ ចឹងនៅពេលដែលសម្តេចយាងមកដល់ហ្នឹងមានអ្នកកាសែតអីទេ?

ពៅៈ មានទាំងអស់ ។

វណ្ណៈ មានច្រើន?

ពៅៈ ចាស ។

វណ្ណៈ ចឹងកងកំលាំងខ្មែរក្រហមនៅហ្នឹងយើងមានទៅទទួលសម្តេចទេ?

ពៅៈ ចាស!ទៅទទួលពួកខ្ញុំអីហ្នឹង ។

វណ្ណៈ ចឹងតាំងនៅព្រៃច្រើនចឹង?

ពៅៈ កាលហ្នឹងមានវាលខ្លះហើយ ដូចថាកន្លែងសម្តេចហ្នឹងវាម៉ុំត្រង់ហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងសម្តេចជិះអីមកទៅ?

ពៅៈ កាលហ្នឹងជិះឡាន តែឡានទុកខាងនេះ ចឹងសម្តេចយាងៗមកចឹងប្រពន្ធទាហានយើងឈរទទួលចឹងទៅជិតដល់សារតាំងទៅ ។

វណ្ណៈ ចឹងខ្ញុំឮគេថាមានជិះដំរីអីដែរ?

ពៅៈ ជិះដំរីមាន ជិះដំរីថ្ងៃត្រឡប់ទៅវិញថ្ងៃវៀតណាមវៃចូលនេះ ថ្ងៃវៀតណាមវាងហ្នឹងឲ្យដំរីសម្តេចជិះមើល ជិះដំរីឆ្លងតាមកន្លែងនោះ ។

វណ្ណៈ ចឹងមកពីថៃសម្តេចយាងមកដោយថ្មើរជើងទេ?

ពៅៈ សម្តេចមកតាមឡាន ឡានថៃជូនមកតែម្តងទាហានថៃ ប៉ូលិសថៃជូនគាត់មក ។

វណ្ណៈ ចឹងឡានអត់មានចូលដីខ្មែរទេ ឡានចតនៅដីថៃ?

ពៅៈ ចាស!ហើយយាងដើរមកតាមស្ពាន ចាប់ពីក្បាលស្ពានយើងឈរអមទទួលរហូត ។

វណ្ណៈ ចឹងមានប្រជាជនច្រើនទេ?

ពៅៈ ប្រជាជនច្រើន ប្រពន្ធទាហានច្រើនដែលហ្នឹង ។

វណ្ណៈ ចឹងនៅពេលទទួលសារតាំងហ្នឹងអត់មានខ្វាចខាងនោះវៃចូលអីទេ?

ពៅៈ អត់មានអីទេ ឃើញមានសភាពការណ៍ស្រួលហើយបានឲ្យស្ដេចមក ។

វណ្ណៈ ចឹងនៅពេលមានវៃគ្នុងក្លាំងមិនហ៊ានឲ្យមកដែរ?

ពៅៈ ចាស ។

វណ្ណៈ ចឹងឧបមាថានៅពេលសម្ដេចមកចឹងស្រាប់តែមានវៃគ្នាក្នុងក្លាំងចឹងយើងម៉េចដឹងការវៃហ្នឹង?

ពៅៈ អត់ដឹង មានកងទ័ពនៅខាងមុខច្រើននោះ ។

វណ្ណៈ ចឹងខាងនេះនិងខាងនោះនិយាយគ្នាត្រូវហើយថាសម្ដេចមកកុំមកវៃចឹង?

ពៅៈ ខ្ញុំមិនដឹងជាម៉េច ។

វណ្ណៈ ចឹងនៅពេលដែលកងទ័ពវៀតណាមដកនៅឆ្នាំ១៩៨៧ សម្ភាររបស់ចិនមានផ្ដល់ឲ្យខាងខ្មែរក្រហមទៀតទេ?

ពៅៈ អត់ទេ ។

វណ្ណៈ ឈប់ហើយ?

ពៅៈ ចាស ។

វណ្ណៈ ចឹងនៅពេលខ្មែរវៃជាមួយគ្នាខ្មែរចិនឈប់ផ្ដល់ហើយ?

ពៅៈ ឈប់ផ្ដល់ហើយ «អ្នកជិតនិយាយថា សូម្បីតែសម្ភារៈដែលចិនយកមកទុកនៅស្រុកថៃហ្នឹង ថៃមិនឲ្យផងថៃយកទាំងអស់មានតិចណា ។

វណ្ណៈ ចឹងថៃបានផលប្រយោជន៍ច្រើនដែរ?

ពៅៈ ចាស! ថៃបានច្រើន ឡានធំៗអីហ្នឹងនៅថៃទាំងអស់ហ្នឹងមានបានណា ។

វណ្ណៈ ចឹងឡានខាងខ្មែរក្រហមហ្នឹង?

ពៅៈ ចាស«អ្នកជិតនិយាយថា កាលហ្នឹងចិនជួយមកមិនទាន់បានដល់ខ្មែរក្រហមណា ។

វណ្ណៈ ចឹងកាំភ្លើងអីថៃបានច្រើនដែរ?

ពៅៈ កាំភ្លើងអាកាអីនៅថៃច្រើន«អ្នកជិតនិយាយថា តាំង១៣០អា១២២អា១០០លី» ។

វណ្ណៈ ចឹងកាលឆ្នាំយើងរស់នៅឆ្នាំ៨៥-៨៦-៨៧-៨៨ចឹងទៀតមានទាហានខ្មែរខាងនោះរត់មកចុះចូលមកជាមួយទាហានខ្មែរក្រហមទេ?

ពៅៈ មានតិចតួច ។

វណ្ណៈ ចឹងមានតិចទេ?

ពៅៈ ចាស!នៅឆ្នាំ៨៧អាចច្រើន ព្រោះកាលហ្នឹងខាងនោះអត់មានបាយហូបនោះទាហានច្រើនហូបអង្ករផ្លដង្កូវច្រើននោះ ។

វណ្ណៈ បាទ ។

ពៅៈ ចឹងវត់មកខាងនេះច្រើន ។

វណ្ណៈ ចឹងកាលចូលមកយើងមានធ្វើបាបដែលអត់?

ពៅៈ អត់មានធ្វើបាបទេ ។

វណ្ណៈ ចឹងមានទាហានប៉ុរាពចូលមកទេ?

ពៅៈ អ្នកជិតនិយាយថា មាន ។

វណ្ណៈ តែកន្លែងនេះតំបន់ខ្មែរក្រហមទេ មានប៉ុរាពដែរ?

ពៅៈ ប៉ុរាពមកធ្វើខ្មែរក្រហមហ្នឹង ។

វណ្ណៈ ចឹងមកធ្វើទេ?

ពៅៈ ចាស!មកធ្វើកូនចៅវត់ចេញមកអង្គភាពនោះមកធ្វើខ្មែរក្រហមចឹងទៅណាស់ ។

វណ្ណៈ ចឹងបើតាមមីងនៅហ្នឹងយូរមីងគិតថាព្រៃឈើនៅម៉ាឡៃនេះអស់នៅឆ្នាំណា?

ពៅៈ ស្រុកម៉ាឡៃយើងអស់ព្រៃឈើប្រហែលជាឆ្នាំ៩៨-៩៩ហ្នឹងអស់តែម្តង ។

វណ្ណៈ ចឹងកាលមុនសមាហរណ៍កម្មនៅឆ្នាំ១៩៩៦នៅមានព្រៃឈើឬអស់ហើយ?

ពៅៈ នៅមានដែលមិនទាន់អស់មែនទែនទេ ។

វណ្ណៈ ចឹងកាលហ្នឹងយើងកាប់លក់ខាងថៃវិញឬខាងណា?

ពៅៈ កាលហ្នឹងកាប់លក់ទៅថៃ កាលហ្នឹងដូចជាគេបើកទំនាក់ទំនងលក់ទៅថៃ កាលហ្នឹងសម្បូរណាស់ឡើងប៉ុនៗនេះឈើ ។

វណ្ណៈ បាទ ។

ពៅៈ នៅកន្លែងសារគាំងអីឈើធំៗណាស់ ។

វណ្ណៈ ខ្ញុំបានដឹងខ្លះៗថា កាលហ្នឹងចិនផ្តាច់ជំនួយហើយយើងអត់មានស្បៀងអីយើងត្រូវកាប់ឈើលក់ទៅថៃខ្លះ?

ពៅៈ ចាស!កាលហ្នឹងមានបរិស័ទគេចូលទំនាក់ទំនងខ្មែរថៃហ្នឹងកាប់លក់ឲ្យថៃខ្លះ ។

វណ្ណៈ ចឹងកាប់លក់ឲ្យថៃខ្លះទៅដល់ស្រុកស្រួលទៅប្រជាជនកាប់យកដីថែមទៀត?

ពៅៈ ចាស ។

វណ្ណៈ ដើម្បីធ្វើចំការអីទៅ?

ពៅៈ ចាស!ដើម្បីធ្វើចំការ ។

វណ្ណៈ ចឹងកាប់ផ្ទះនេះខ្លះទៅដើម្បីយកដីធ្វើចំការមែនទេ?

ពោះ ចាស ។

វណ្ណៈ ចឹងនៅពេលកាប់ឆ្កាយកដីហ្នឹងមានប្រជាជនជាន់មីនផ្ទុះដាច់ជើងដាច់ដៃស្លាប់ច្រើនទេ?

ពោះ មានដាច់ពិការច្រើន ស្លាប់ច្រើន កាលហ្នឹងស្លាប់ម្តងទៀត មីនមានពេញព្រៃ ។

វណ្ណៈ មីនមានច្រើន?

ពោះ ចាស!មើលដីបូងមកនៅនេះ ក្មួយស្រីផងដាច់ជើងទាំងពីរ គាត់ទៅកាប់ទ្រើងដាំត្រឡាចណាស់ ។

វណ្ណៈ បាទ ។

ពោះ នៅកំព្រាកូនសព្វថ្ងៃ នៅកាប់ទ្រើងត្រឡាចហ្នឹងទាញមកដាច់ជើងទាំងពីរស្លាប់ទៅមានរស់ណា ។

វណ្ណៈ បាទ ។

ពោះ ហើយប្រុសៗចឹងដែលឈូសដីកន្លែងធ្វើផ្ទះហ្នឹង ឈូសៗទៅដាច់ជើងហ្នឹងនៅពិការដល់រាល់ថ្ងៃហ្នឹង ។

វណ្ណៈ ចឹងខ្ញុំចង់សួរមីងៗបកទៅវិញខ្លះៗដែរ កាលមីងចេញពីផ្ទះទៅហ្នឹងកាលហ្នឹងមីងស្មគ្រ័ចិត្តទៅឬមួយគេបង្ខំឲ្យមីងទៅ?

ពោះ កាលចេញពីផ្ទះហ្នឹងគេសុទ្ធតែបង្ខំឲ្យទៅ ។

វណ្ណៈ ចឹងគេបង្ខំ?

ពោះ ចាស!សម័យហ្នឹងគេបង្ខំឲ្យទៅ អត់មានឲ្យយើងនៅជាមួយឪពុកម្តាយទេ ទោះអ្នកណានៅក៏ដោយត្រូវតែចេញទាំងអស់ កាលស្រុកខ្ញុំហ្នឹងចេញទៅទាំងអស់តែម្តង ខ្លះនៅតាមភូមិភាគទៅខ្លះនៅតាមស្រុកទៅ ។

វណ្ណៈ បាទ ។

ពោះ ខ្ញុំកាលហ្នឹងនៅស្ទើរជាងគេដូចថាមួយភូមិហ្នឹង ខ្ញុំរៀងតូចជាងគេ គេថាមិនឲ្យខ្ញុំទៅភូមិភាគទេឲ្យខ្ញុំនៅត្រឹមស្រុក តែខ្ញុំនឹកឃើញថាបើខ្ញុំនៅស្រុកក៏មិនបាននៅជាមួយឪពុកម្តាយ ។

វណ្ណៈ បាទ ។

ពោះ ចឹងខ្ញុំសុខចិត្តចេញមកឆ្ងាយមកភូមិភាគចុះ គិតថាភូមិភាគហ្នឹងវាទូលាយជាងស្រុកបន្តិចណាស់អូន ។

វណ្ណៈ បាទ

ពោះ នឹកឃើញការហូបចុកអីម្យ៉ាងការគ្រប់គ្រងអីវាទូលាយជាងនៅស្រុក ទោះបីខ្ញុំនៅស្រុកក៏មិនបាននៅជាមួយឪពុកម្តាយ ។

វណ្ណៈ យ៉ាងម៉េចចឹង?

ពៅៈ ចឹងខ្ញុំប្រាប់ម៉ែខ្ញុំថា ចុះនៅស្រុកក៏គេគៀរចេញមកនៅចល័តទាំងអស់អត់មានអ្នកលីវៗ នៅជាមួយឪពុកម្ដាយទេ ។

វណ្ណៈ បាទ ។

ពៅៈ ចឹងបានម៉ែខ្ញុំគាត់ផ្ដាំថា កូនកុំរត់មកផ្ទះវិញកុំឲ្យគេធ្វើបាប ។

វណ្ណៈ បាទ ។

ពៅៈ សុខអត់ស៊ីមានស៊ីក៏ដោយកូនតស៊ូខ្លាច ដូចថារត់មកផ្ទះទៅក្រែងមានគេខចាប់គេចងអីទៅគាត់ពិបាកណាស់ ។

វណ្ណៈ បាទ ។

ពៅៈ គាត់ទុកចិត្តមិនបានគាត់អាណិតអីចឹង ខ្ញុំសុខចិត្តតាមដូចគាត់ផ្ដាំចឹង ហត់ពិបាកឡើយយ៉ាងម៉េចក៏មិនហ៊ានទៅផ្ទះដែរ ។

វណ្ណៈ បាទ ។

ពៅៈ ជីដូនមួយខ្ញុំអីបានទៅផ្ទះវិញ អត់តែខ្ញុំហ្នឹងឯង ។

វណ្ណៈ ចឹងកាលនៅស្រែអំបិលមីងមានធ្វើអីដែលបើមីងទៅតែមួយភ្លេតចឹង?

ពៅៈ ទៅស្រែអំបិលទៅដល់គេឲ្យរែកអំបិលតែម្ដង បន្ទាប់ដីបុកអន្លុបស្រែអំបិលចឹងជាងផង ច្រៀងផងបុកអន្លុបផង ។

វណ្ណៈ គេថាទាល់តែច្រៀងបានបុកត្រូវ?

ពៅៈ ចាស!ទាល់តែច្រៀងទៅបានបុកអន្លុបស្រុះគ្នានោះ ។

វណ្ណៈ ហើយសប្បាយដែលកាលហ្នឹង?

ពៅៈ កាលហ្នឹងកំលាំងនៅពេញចេះតែសប្បាយហើយ នៅក្មេងៗចឹងមានអី ។

វណ្ណៈ ចឹងកាលនៅស្រែអំបិលហូបចុកបបូរទេ?

ពៅៈ នៅស្រែអំបិលគ្រាន់បើអត់មានអីទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានដែលសរសេរសំបុត្រសួរសុខទុក្ខម្ដាយឪពុកមានដែលមកលេងផ្ទះដែរ?

ពៅៈ អត់ទេ ឆ្ងាយណាស់មិនដឹងជាដើរតាមណាទេ ពីស្រុកខ្ញុំនៅកំពតឆ្ងាយណាស់ ។

វណ្ណៈ បាទ ។

ពៅៈ ខ្ញុំបានសរសេរសំបុត្រកាលនៅភ្នំពេញ ។

វណ្ណៈ ចឹងកាលនៅភ្នំពេញ?

ពៅៈ ចាស!នៅភ្នំពេញហ្នឹងកាលឆ្នាំ៧៨ហ្នឹង សរសេរសំបុត្រផ្ញើរទៅផ្ទះប្រាប់ឪពុកម្ដាយខ្ញុំថាខ្ញុំនៅរស់ទេ ។

វណ្ណៈ   បាទ ។

ពោះ   ចាំថ្ងៃ  កាលហ្នឹងគេរត់ថ្ងៃមួយខ្ញុំថា  ប្រហែលជាមុនចូលឆ្នាំខែ២ឬខែ៣ហ្នឹងកន្លែងអន្តភាពគេហ្នឹង គេឲ្យទៅលេងឪពុកម្ដាយហើយ  មានណាគ្រាន់តែថ្ងៃទី១ខែ១ហ្នឹងរត់បណ្ដោយ ។

វណ្ណៈ   បាទ ។

ពោះ   មានបានទៅណា  តែគ្រាន់ដឹងថាឪពុកម្ដាយខ្ញុំដឹងថាខ្ញុំនៅរស់ ។

វណ្ណៈ   បាទ ។

ពោះ   តែដល់ក្រោយមកទៀតបាត់ដំណឹងឈឹងទៅ   ចែខ្ញុំគាត់និយាយម្ដាយខ្ញុំជួលគេដើររកលក់មាសអី ដើររកខ្ញុំដល់ភ្នំឆត្រព្រៃមាន់នេះ ។

វណ្ណៈ   បាទ ។

ពោះ   ដល់រកមិនឃើញគាត់ដាក់តាមប៉ុស្តិ៍វិទ្យុនៅភ្នំពេញ    រកយ៉ាងម៉េចឃើញនៅខ្មែរក្រហមណាគេឲ្យ មានវិទ្យុស្ដាប់ ។

វណ្ណៈ   ចឹងហើយកាលបាត់កូននៅឆ្នាំ១៩៧៩ហ្នឹងរកកូនសឹងគ្រប់តែគ្នាហ្នឹង?

ពោះ   ចាស ។

វណ្ណៈ   ខ្លះខ្ញុំដើរធ្វើការតាមភូមិហ្នឹងមានអ្នកខ្លះរកគ្រូ១០ទៅ២០គ្រូអីនោះដោយសារបាត់កូន?

ពោះ   ចាស ។

វណ្ណៈ   ចឹងកាលមីងនៅស្រែអំបិលហ្នឹង  ដូចថាប្រធានមីង  មីងមាននៅចាំទេ?

ពោះ   នៅស្រែអំបិលប្រធានខ្ញុំមួយឈ្មោះបងផល ។

វណ្ណៈ   ចឹងគាត់ចិត្តល្អដែរ?

ពោះ   គាត់ចិត្តល្អដែលទេ  ខ្ញុំបានបងផលហ្នឹងហើយគាត់ជួយនោះ ។

វណ្ណៈ   ចឹងគាត់នៅរស់ទេបងផលហ្នឹង?

ពោះ   ឥឡូវខ្ញុំបែកគាត់កាលចេញពីភ្នំពេញមកហ្នឹង  ខ្ញុំជួបគាត់កាលនៅលាចម្ដង ។

វណ្ណៈ   បាទ ។

ពោះ   គាត់មានប្ដី  ដល់ពេលមានប្ដីទៅ  ប្ដីគាត់យោធានោះដល់ហើយជួបបានមួយភ្លេតហ្នឹងគាត់នៅអន្ត ភាពផ្សេងខ្ញុំក៏រត់មកទៀតទៅណាស់ ។

វណ្ណៈ   ចឹងកាលនៅកំពង់សោមធ្វើចំការកៅស៊ូ?

ពោះ   នៅចំការកៅស៊ូហ្នឹងវានឿយដែលម៉ោង៣ជិតភ្លឺហ្នឹងគេដាស់ងើបហើយ  ងើបដើរចំការកៅស៊ូហ្នឹង ជិតវាលវិញនោះ  ឡើងភ្នំចុះភ្នំរហូត  ងើបពីម៉ោង៣ទំរាំដល់ចំការកៅស៊ូម៉ោងជិត៧ព្រឹក ។

វណ្ណៈ   បាទ ។

ពៅៈ ដើររហូត កាលហ្នឹងពេញដេកផងដើរបណ្ដើរផក់បណ្ដើរតាមថ្នល់ជាតិ ។

វណ្ណៈ ចឹងមានគ្នាច្រើនទេ?

ពៅៈ មានគ្នា៥០០នាក់ ។

វណ្ណៈ ចឹងក្នុង៥០០នាក់ហ្នឹង កាលជំនាន់ហ្នឹងមានបាត់ខ្លួនខ្លះទេ?

ពៅៈ ៥០០នាក់កាលខ្ញុំនៅចំការកៅស៊ូហ្នឹងមិនមានបាត់ទេ ។

វណ្ណៈ ចឹងអត់មានបាត់ទេ?

ពៅៈ អាចមកក្រោយៗមានបាត់ខ្ញុំមិនបានដឹងទេណាស់ ។

វណ្ណៈ ចឹងពេលមឹងមកដល់ភ្នំពេញ?

ពៅៈ មកដល់ភ្នំពេញទៅតាមរោងចក្រផ្សេងៗគ្នាទៅ ។

វណ្ណៈ ចឹងកាលនៅរោងចក្រហ្នឹងប្រធាន?

ពៅៈ ប្រធានរោងចក្រខ្ញុំបងធីនៅចក្រីរាល់ថ្ងៃ ។

វណ្ណៈ ចឹងប្រធានមុនហ្នឹងទៀត?

ពៅៈ ប្រធានមុនហ្នឹងគេចាប់បាត់ ខ្ញុំចូលទៅដល់ហ្នឹងប្រហែលជា១០ថ្ងៃគេចាប់ប្រធានរោងចក្រហ្នឹងបាត់ ។

វណ្ណៈ បាទ ។

ពៅៈ គេបញ្ជូលមកធីហ្នឹងមកពីស្រែអំបិល ប្រធានកងវរៈពួកខ្ញុំនៅចំការកៅស៊ូហ្នឹងបញ្ជូលបងធីហ្នឹងគ្រប់គ្រងរោងចក្រហ្នឹងវិញ ។

វណ្ណៈ បាទ ។

ពៅៈ ហើយបងធីហ្នឹងគាត់នៅរាល់ថ្ងៃហ្នឹង ។

វណ្ណៈ ចឹងថាឈ្មោះខុមបងប្អូនមឹងថាស្លាប់នោះ ឈ្មោះអីខ្ញុំច្រឡំបងប្អូនមឹងបង្កើតឈ្មោះអីទៅ?

ពៅៈ បងខ្ញុំឈ្មោះបង គៀតហ្នឹងស្លាប់នៅស្រុកកោះធំ ។

វណ្ណៈ ចឹងគាត់ស្លាប់ដោយសារតែមូលហេតុអីទេ?

ពៅៈ ស្លាប់ហ្នឹងចេះកាលខ្ញុំបែកឆ្នាំ៩៣ហ្នឹង កាលអ៊ុនតាក់ចូលខ្ញុំទៅលេងស្រុកពេលរួចទៅជួបក្មួយៗបងប្អូនចេះតែយំសោករាប់រៀបថាស្លាប់អស់ចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ពៅៈ គាត់ថាបងខ្ញុំហ្នឹងមុនដំបូងគេចាត់តាំងឲ្យធ្វើជាទាហានសហករណ៍ ។

វណ្ណៈ បាទ ។

ពៅៈ ដល់ពេលរួចទៅដូចថាអង្គការដាក់ពិន័យឲ្យប្រជាជនហូបបបរចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ពោះ គាត់នឹកឃើញអាណិតប្រជាជនហូបបបរគ្មានកំលាំងធ្វើការចឹង គាត់ប្រាប់អ្នកដាំបាយមីង១ហ្នឹង ចែកបងប្អូនមួយចានក៏ដោយកន្លះចានក៏ដោយហូបបាយទៅវាហ្នឹងពោះ ។

វណ្ណៈ បាទ ។

ពោះ យើងធ្វើការបាន យើងហូបបបររាវហូបមួងអស់ហើយ បងខ្ញុំគាត់ប្រជុំប្រាប់ចឹង ក្រោយមក គេដកបងខ្ញុំចេញ គេថាបងខ្ញុំហ្នឹងក្បត់ ។

វណ្ណៈ បាទ ។

ពោះ ដល់ពេលសួរទៅក្រោយមកទៀតគេយកបងខ្ញុំហ្នឹងមកធ្វើកាណូត ទៅធ្វើម៉ាស៊ីនកាណូតបានតែ ប៉ុន្មានខែគេយកបងខ្ញុំទៅសម្លាប់ចោល ។

វណ្ណៈ ចឹងរឿងហ្នឹងមីងបានដឹងនៅពេលដែលមីងបានត្រឡប់ទៅស្រុកវិញ?

ពោះ ចាស ។

វណ្ណៈ ចឹងបងមួយទៀត?

ពោះ បងមួយទៀតហ្នឹងឈ្មោះ ទុយគាត់ធ្វើប៉ូលីសជំនាន់សម្តេច ។

វណ្ណៈ ចឹងឈ្មោះទុយ?

ពោះ ចាស ។

វណ្ណៈ ចឹងទុយហ្នឹងស្លាប់នៅជំនាន់ណាដែរ?

ពោះ គាត់ស្លាប់ជំនាន់ហ្នឹងដែលគេជម្លៀសពីភ្នំពេញទៅ ។

វណ្ណៈ ចឹងមិនដឹងថាមូលហេតុអីទេ?

ពោះ ខ្ញុំឮបងថ្លៃខ្ញុំនិយាយថា គេជម្លៀសយកទៅក្អមសំណាហ្នឹងស្លាប់នៅហ្នឹងឯង ។

វណ្ណៈ បាទ ។

ពោះ ស្លាប់ទាំងក្មួយទាំងអស់ហ្នឹងនៅតែបងថ្លៃ ។

វណ្ណៈ ស្លាប់អស់ច្រើនដែរ?

ពោះ ស្លាប់អស់ប្អូននាក់នៅបងថ្លៃកូនក៏ស្លាប់បងប្រុសក៏ស្លាប់នៅតែប្រពន្ធបងថ្លៃខ្ញុំនៅភ្នំពេញសព្វថ្ងៃ ហ្នឹង កាលមុនគាត់ធ្វើការខាងកាកបាទដែរ ឥឡូវបែបគាត់អាត្រែតហើយមើលទៅ ។

វណ្ណៈ ចឹងមីងកាលសម័យខ្មែរក្រហមមីងមិនដែលបានទៅលេងផ្ទះសោះ?

ពោះ អត់សោះ ។

វណ្ណៈ ចឹងរហូតដល់សមាហរណ៍កម្មហ្នឹង?

ពោះ ចាស!រហូតដល់ឆ្នាំ៩៣ហ្នឹងបានខ្ញុំទៅលេង ។

វណ្ណៈ ចឹងកាល៩៣អ៊ុនគាត់ចូល?

ពៅៈ មីមួយនេះទៅបៅដោះនៅឡើយខ្ញុំលួចទៅបណ្តោយ ។

វណ្ណៈ ចឹងអ៊ុនគាត់មានចូលមកដល់ហ្នឹងទេ?

ពៅៈ អ៊ុនគាត់មិនទាន់ចូលទេ កាលហ្នឹង ។

វណ្ណៈ ចឹងអ៊ុនគាត់ចូលនៅត្រឹមខេត្តទេ?

ពៅៈ អ៊ុន គាត់មិនទាន់ចូលតែម្តង ខេត្តក៏មិនទាន់ចូល ។

វណ្ណៈ អត់ទេ ៩៣ចូលដល់ខេត្តហើយ?

ពៅៈ ៩៣ចូលហើយខ្ញុំលួចទៅមុនហ្នឹង ។

វណ្ណៈ ចឹងអ៊ុនគាត់មិនហ៊ានចូលដល់ម៉ាឡៃទេ?

ពៅៈ ចាស!នៅក្នុងអ៊ុនគាត់មិនទាន់ចូលដែរ ខ្ញុំលួចទៅតាមផ្លូវប៉ោយប៉ែតនេះ អ៊ុនគាត់ទើបចូលដល់ដើមពោធិបីដើម ទើបមានស្ពានរវមីនអីនៅហ្នឹងទេ ចឹងតាមខេត្តមិនទាន់មានអ៊ុនគាត់ចូលទេ ។

វណ្ណៈ ចឹងកាលបោះឆ្នោតអ៊ុនគាត់អត់ចូលមកដល់នេះទេ មីងមិនបានបោះឆ្នោតទេមែនទេ?

ពៅៈ អត់ទេ ។

វណ្ណៈ ព្រោះខ្មែរក្រហមផ្តាច់ខ្លួនមិនព្រមចូលរួមបោះឆ្នោត ចឹងនៅតំបន់ម៉ាឡៃហ្នឹងខ្មែរក្រហមមិនចូលរួមបោះឆ្នោតទេកាលហ្នឹង៩៣ហ្នឹង?

ពៅៈ ចាស ។

វណ្ណៈ ចឹងហើយអ៊ុនគាត់ក៏មិនបានចូលដល់នេះដែរ?

ពៅៈ អត់ទេ ។

វណ្ណៈ ចឹងមីងទៅស្រុកកំណើតបានប៉ុន្មានដងមីង?

ពៅៈ កាលម្តាយខ្ញុំនៅរស់ខ្ញុំទៅបានបីដង ឥឡូវខ្ញុំទៅញឹកដែរ ។

វណ្ណៈ ចឹងខស្សាហ៍ទៅដែរ?

ពៅៈ ទៅថ្ងៃមុនឪពុកមាឈឺទើបតែមក តែកាលម្តាយខ្ញុំនៅរស់ខ្ញុំទៅជួបគាត់បានបីដង ។

វណ្ណៈ ចឹងឪពុក?

ពៅៈ ឪពុកអត់បានជួបទេ គាត់ស្លាប់តាំងពីឆ្នាំ៧៤ ។

វណ្ណៈ ចឹងទៅមិនទាន់ទេ?

ពៅៈ ចាស!គាត់ចាស់ៗហើយ ខ្ញុំកូនពៅនោះ ។

វណ្ណៈ ចឹងឥឡូវនៅបងប្អូនខ្លះដែរ?

ពៅៈ នៅតែបងមួយ ។

វណ្ណៈ ចឹងមានបងប្អូនមកនៅជាមួយទេ?

ពៅៈ អត់នៅតែម្នាក់ឯង ។

វណ្ណៈ ចឹងឥឡូវគិតថានៅនេះរហូតឬយ៉ាងម៉េចទៅថ្ងៃអនាគត?

ពៅៈ រាល់ថ្ងៃហ្នឹងទាក់ទើ ណាមួយកូនចៅនៅនេះទាំងអស់ហើយ ចិត្តមួយថាចង់នៅនេះចិត្តមួយគិតថា បើសិនណាកូនចៅគេមានប្ដីមានប្រពន្ធអស់ ចង់តែទៅនៅជុំបងប្អូនហើយខ្ញុំ រាល់ថ្ងៃវៀងពិបាក បន្ដិចថាមានរវល់បងប្អូននៅឆ្ងាយណាស់ នៅនេះម្នាក់ឯងពិបាកទៅពិបាកមក ។

វណ្ណៈ នៅនេះបន្តិចទៅគេធ្វើផ្តល់ជាតិទៅត្រូវប៉ុន់ហើយ?

ពៅៈ ចាស ។

វណ្ណៈ ខ្ញុំឮថាជិតធ្វើផ្តល់ហើយតើ?

ពៅៈ ចាស!ឮថាថ្ងៃទី២០នេះ ចុះឈ្មួសហើយមិនដឹងជាយ៉ាងម៉េចបើទឹកចឹង ។

វណ្ណៈ បាទ!ភ្លៀងចឹងពិបាកផ្លូវទៅមក?

ពៅៈ ពិបាកផ្លូវណាស់ ។

វណ្ណៈ ចឹងកាលមីងរត់មកដល់ដំបូងមីងមានដឹងថាម៉ាឡៃហ្នឹងនៅតំបន់ណាខេត្តណាមានដឹងទេមីង?

ពៅៈ កាលឆ្នាំ៧៩ ។

វណ្ណៈ បាទ!កាល៧៩?

ពៅៈ អត់ទេ ម៉ាឡៃហ្នឹងដូចជាទើបក៏កើតក្រោយយ៉ាងម៉េច ខ្ញុំមកនៅដំបូងមានដឹងថាម៉ាឡៃអីផង ។

វណ្ណៈ ចឹង?

ពៅៈ អត់មានឮគេនិយាយផង ។

វណ្ណៈ ចឹងម៉ាឡៃហ្នឹងឮច្បាស់នៅឆ្នាំណា?

ពៅៈ ដឹងច្បាស់គេថាឆ្នាំ៨០-៨១ហើយគេថាភ្នំម៉ាឡៃៗកកើតម៉ាឡៃទៅដំបូងគេហៅតែភូមិដូងហ្នឹង ។

វណ្ណៈ បាទ ។

ពៅៈ ភូមិដូងហ្នឹងភូមិដូងថៃទៀតហ្នឹងណាស់ ។

វណ្ណៈ ចឹងនៅឆ្នាំណាបានកើតជាស្រុកម៉ាឡៃនេះ?

ពៅៈ ឆ្នាំណា កាល៧៩យើងមិនទាន់មានស្រុកទេ យើងគ្រាន់តែដឹងថាភ្នំម៉ាឡៃ ឆ្នាំ៨០ហ្នឹងគេដាក់ថា ភ្នំម៉ាឡៃ ភ្នំហ្នឹងគេដាក់ភ្នំម៉ាឡៃអត់មានស្រុកទេ ។

វណ្ណៈ ចឹងគេហៅថាភូមិដូងទេ?

ពៅៈ ហៅថាភូមិដូងទេ ។

វណ្ណៈ ចឹងក្រោយមកដឹងថាភ្នំម៉ាឡៃ?

ពៅៈ ចាស ។

វណ្ណៈ កើតស្រុកច្បាស់នៅពេលណា?

ពៅៈ កើតស្រុកច្បាស់ដូចជាយើងបោះឆ្នោតកាលឆ្នាំ៩៣ទេ... ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយបានកើតស្រុកម៉ាឡៃឬយ៉ាងម៉េច?

ពៅៈ ចាស!ហ្នឹងហើយ សមាហរណ៍កម្មហើយបានមានសាលាស្រុក ចូលខេត្តបន្ទាយមានជ័យហ្នឹង បានកើតស្រុកម៉ាឡៃបណ្តោយ កាលមុនគេហៅតំបន់៣២ហើយយើងគេហៅអីគេហ្នឹងហើយគេហៅ១០២យើងនេះ តំបន់១០២ហ្នឹងឯង ។

វណ្ណៈ ចឹងតំបន់១០២គេហៅនៅពេលណា?

ពៅៈ ហៅតាំងពីយើង៧៩មករហូតដល់ឆ្នាំ៩៦ គេហៅតំបន់១០២ហ្នឹង ។

វណ្ណៈ ចឹងមានមូលហេតុអីបានជាគេដាក់ថាតំបន់១០២ហ្នឹង?

ពៅៈ គេដាក់ជាចំណុចខ្មែរក្រហមគេកាន់កាប់ ខ្ញុំដឹងថាតំបន់១០២កងពល៤៥០ចាំតែប៉ុណ្ណឹងឯង ដូចជាតា សុខ ភាពហ្នឹងគាត់គ្រប់គ្រងកងពល៤៥០ចឹងយើងដឹង ។

វណ្ណៈ កងពល៤៥០ហ្នឹងមានតែកងពលហ្នឹងមួយទេ នៅហ្នឹង?

ពៅៈ មានតែកងពលហ្នឹង ។

វណ្ណៈ ចឹងមានតែកងពលហ្នឹងទេ?

ពៅៈ ចាស ។

វណ្ណៈ តែវាមានវរៈសេនាធំមានវរៈសេនាតូចបន្តទៀត?

ពៅៈ ចាស!វរៈសេនាធំវរៈសេនាតូចកងធំកងតូចថ្នាក់ៗមក ។

វណ្ណៈ ចឹងមីងធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហមហើយឆ្លងកាត់មកដល់ឥឡូវទៀត កាលមីងនៅភ្នំពេញជំនាន់ខ្មែរក្រហមហ្នឹងមីងមានដឹងថាមានការសម្លាប់មនុស្សអីទេ?

ពៅៈ កាលហ្នឹងខ្ញុំអត់ដឹងទេ មានអ្នកភូមិជាមួយខ្ញុំនៅរោងចក្រថាមពលណាស់ ។

វណ្ណៈ បាទ ។

ពៅៈ រោងចក្រថាមពលហ្នឹងជាប់រោងចក្រខ្ញុំចឹង គេអ្នកភូមិជាមួយគ្នា ។

វណ្ណៈ បាទ ។

ពៅៈ ចឹងអ្នកទៅលេងផ្ទះហ្នឹងមកខ្សិបប្រាប់ខ្ញុំថា បើឯងចង់ទៅលេងផ្ទះឯងមិនបាច់ទៅក៏បានដែរ វេទនាណាស់ស្រុកភូមិយើងគេធ្វើបាបណាស់ឪពុកម្តាយមិនមានអីហូបទេ ហូបបបររាវៗហើយបងប្អូនឯងវេទនាណាស់គេធ្វើបាបណាស់ ។

វណ្ណៈ ចឹង?

ពោះ	វាឪ្យបប្រាប់ខ្ញុំថាបើនៅលេងផ្ទះមិនបាច់ទៅទេ ស្រួលតែពួកយើងនៅភ្នំពេញទេ ។

វណ្ណៈ	បាទ ។

ពោះ	បើតាមសហករណ៍ឯងមិនបាច់ទៅក៏បានដែរ វាប្រាប់ខ្ញុំចឹង ។

វណ្ណៈ	បាទ ។

ពោះ	ដល់ពេលរត់៧៩មកវាបែកគ្នាវាទៅខាងសំឡូត ដល់ប្តីវាស្លាប់ទៅវាទៅនៅស្រុកវិញ ។

វណ្ណៈ	បាទ ។

ពោះ	ខ្ញុំទៅលេងស្រុកជួបនៅស្រុក វាចាស់ហើយឥឡូវ ។

វណ្ណៈ	បាទ ។

ពោះ	កាលហ្នឹងខ្ញុំមានបានទៅលេងផ្ទះណារហូតតាំងពីហ្នឹងមក ។

វណ្ណៈ	ចឹងមីងយល់ថា ជំនាន់ខ្មែរក្រហមបីឆ្នាំប្រាំបីខែម្ភៃហ្នឹងកាលស្លាប់របស់ប្រជាជនជាកំហុសអ្នកដឹកនាំឬមួយជាកំហុសអ្នកដឹកនាំខាងក្រោមតាមយោបល់មីងគិត?

ពោះ	តាមគំនិតខ្ញុំគិតថា ជាកំហុសអ្នកដឹកនាំខាងលើតិចទេ សំខាន់កំហុសអ្នកដឹកនាំថ្នាក់ក្រោយគឺខ្លាំងព្រោះខាងលើដាក់ប្រវ៉ែងមួយថ្នាំងដៃចឹង ខាងក្រោមដាក់ដល់មួយចង្អាមចឹងបងប្អូនខ្ញុំស្លាប់នៅក្នុងក៏អត់មានអ្នកខាងលើមកបញ្ជាដែរ ចឹងការស្លាប់របស់បងប្អូនខ្ញុំហ្នឹងគឺមានតែអ្នកនៅក្នុងស្រុកត្រឹមស្រុកត្រឹមតំបន់ហ្នឹងឯង ។

វណ្ណៈ	ចឹងថ្នាក់ក្រោមមានកំហុសធ្ងន់?

ពោះ	ចាស!ថ្នាក់ក្រោមហ្នឹងគឺធ្ងន់តែម្តង គាត់អត់មានតាមដានវិនិច្ឆ័យថាមនុស្សល្អអាក្រក់យ៉ាងម៉េចឲ្យតែមានទំនាស់មិនសមរម្យតិចតួចយកទៅសម្លាប់ ។

វណ្ណៈ	បាទ ។

ពោះ	ដូចជាបងខ្ញុំអីគាត់ជាមនុស្សល្អណាស់ ។

វណ្ណៈ	បាទ ។

ពោះ	គាត់ជាមនុស្សស្លូតត្រង់ បងប្អូនគោរពស្រឡាញ់ទាំងអស់ដូចថានៅស្រុកភូមិអ្នកណាខ្វះខាតអីទៅរកតែគាត់ទេ គាត់ជាមនុស្សចិត្តល្អ ។

វណ្ណៈ	ចិត្តល្អស្លាប់ហើយជំនាន់ហ្នឹង?

ពោះ	ចាស ។

វណ្ណៈ	ហើយកាលហ្នឹងគេសំដៅរកអ្នកចេះដឹង ខ្មែរក្រហមគេមានគោលដៅមួយបើទុកអ្នកចេះដឹងគេពិបាកប្រើ ។

ពោះ: ចាស ៗ !តវ៉ាបន្តិចបន្តួចដូចជាបងខ្ញុំអីគាត់យល់ថាប្រជាជនហ្នឹងបបរវ៉ាអត់មានកំលាំងធ្វើការវ៉ា ពិបាកគាត់ថាឲ្យជាមបាយចែកគ្នាទៅទោះតិចតួចអី ចឹងគាត់អាណិតប្រជាជនណាស់បានជាគាត់ គិតចឹង មិនទៅជាចឹងគេថាបងខ្ញុំហ្នឹងក្បត់ ។

វណ្ណៈ: បាទ ។

ពោះ: គេយកគាត់ទៅសម្លាប់វិញ មានអ្នកលើណាដឹង ។

វណ្ណៈ: បាទ ។

ពោះ: តែខាងលើហ្នឹងក៏ខុះខាតដែរ ការដឹកនាំរបស់គាត់ហ្នឹងដូចថាមិនតាមដានឲ្យច្បាស់លាស់ណាស់ និយាយថាមិនដូចជាឥឡូវមានអ្នកតាមដានពីថ្នាក់ក្រោមរហូតដល់លើ ។

វណ្ណៈ: ចឹងស្រុកម៉ាឡៃទើបតែកើតស្រុកនៅពេលដែលមានការបោះឆ្នោតហើយត្រូវគ្នាទេ បានកើត មានស្រុកម៉ាឡៃ?

ពោះ: ចាស ។

វណ្ណៈ: ចឹងមីងគិតថាទៅមុខទៀតម៉ាឡៃសប្បាយដូចជាគេនៅខាងក្នុងអីដែលទេឬយ៉ាងម៉េចដែរ?

ពោះ: តាមចិត្តខ្ញុំគិតថាអនាគតទៅបែបសប្បាយដែរ ។

វណ្ណៈ: សប្បាយជាងឬយ៉ាងម៉េច?

ពោះ: ចាស!ប្រហែលជាសប្បាយជាង ។

វណ្ណៈ: យ៉ាងម៉េចគិតថាសប្បាយជាង?

ពោះ: ព្រោះនៅជិតព្រំដែន បើធ្វើចំការបានលុយច្រើនអីប្រហែលជាសប្បាយដូចនៅតាមខេត្តដែល មើលទៅ ។

វណ្ណៈ: បាទ ។

ពោះ: វ៉ាមិនដូចតាមជនបទណាស់ ។

វណ្ណៈ: ចឹងទៅថ្ងៃអនាគតមិនចង់ឲ្យគេបែងចែកជាខ្មែរក្រហមចង់ឲ្យគេនិយាយថាជាខ្មែរតែមួយឬយ៉ាង ម៉េច?

ពោះ: សព្វថ្ងៃខ្ញុំមិនចង់ឲ្យមានខ្មែរក្រហមទៀតទេ និយាយទៅចង់ឲ្យមានខ្មែរតែមួយ ។

វណ្ណៈ: ចឹងមិនប្រកាន់ថាខ្មែរខាងនេះខាងនោះទេ?

ពោះ: ចាស!មិនចង់ឲ្យមានខ្មែរក្រហមខ្មែរក្នុងខ្មែរក្រៅអីទេ ។

វណ្ណៈ: ចឹងមីងមានគំនិតចង់ផ្សះផ្សាឲ្យប្រជាជនខ្មែរដូចគ្នារួបរួមគ្នាឡើងវិញ?

ពោះ: ចាស!ចឹងឲ្យខ្មែរមានតែមួយបានហើយ ។

វណ្ណៈ: បាទ ។

ពៅៈ បើខ្មែរមានពីរបីពិបាកណាស់ ។

វណ្ណៈ ចឹងមឹងមានអីចង់និយាយទៀតខ្ញុំដូចជាអស់សំនួរសួរមឹងហើយ?

ពៅៈ ខ្ញុំមិនដឹងជានិយាយអីដែរ ខ្ញុំស្តាយដែលមកសួរហ្នឹង ។

វណ្ណៈ ចឹងខ្ញុំអរគុណមឹងច្រើនហើយ ។

ពៅៈ ចាស ។

**«ចប់»**